រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

007KH01A-01

អត្ថបទសិក្សា ទី ៤

ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៧

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ត្រូវចូលរួមធ្វើពិធីជប់ល្បែងរបស់ព្រះអម្ចាស់ (ពិធីកាច់នំបុ័ង)

ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំហ្នឹងហើយជាដើមទំពាំងបាយជូរ ដ៏ពិតប្រាកដ រីឯព្រះបិតាខ្ញុំ ជាម្ចាស់ចំការ ។ មែកណានៅជាប់នឹងខ្ញុំ តែឥតមានផ្លែ ព្រះបិតាកាត់មែកនោះចោល ។ រីឯមែកណាមានផ្លែ ព្រះអង្គលួសមែកនោះ ដើម្បីអោយមានផ្លែកាន់តែច្រើនឡើងទៀត ។ ពាក្យដែលខ្ញុំបានប្រាប់ ធ្វើអោយអ្នករាល់គ្នាបរិសុទ្ធរួចទៅហើយ ។ ចូរស្ថិតនៅជាប់នឹងខ្ញុំ ដូចខ្ញុំស្ថិតនៅជាប់នឹងអ្នករាល់គ្នាដែរ ។ ប្រសិនបើមែកមិនស្ថិតនៅជាប់នឹងដើមទេ វាពុំអាចបង្កើតផលដោយឯកឯងបានឡើយ ។ រីឯអ្នករាល់គ្នាក៏ដូច្នោះដែរ បើមិនស្ថិតនៅជាប់នឹងខ្ញុំទេ អ្នករាល់គ្នាពុំអាចបង្កើតផលបានទាល់តែសោះ ។

ខ្ញុំនេះហើយជាដើមទំពាំងបាយជូរ អ្នករាល់គ្នាជាមែក អ្នកណាស្ថិតនៅជាប់នឹងខ្ញុំ ហើយខ្ញុំនៅជាប់នឹងអ្នកនោះ ទើបអ្នកនោះបង្កើតផលបានច្រើន ។ បើដាច់ពីខ្ញុំ អ្នករាល់គ្នាពុំអាចធ្វើអ្វីកើតឡើយ ។ អ្នកណាមិនស្ថិតនៅជាប់នឹងខ្ញុំ អ្នកនោះប្រៀបដូចជាមែកដែលគេបោះចោលទៅខាងក្រៅ ហើយស្វិតក្រៀម ។ បន្ទាប់មក គេរើសមែកទាំងនោះបោះទៅក្នុងភ្លើងឆេះអស់ទៅ ។

សូមទន្ទេញ

«បន្ទាប់មក ព្រះអង្គយកនំបុ័ងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចព្រះអង្គកាច់ប្រទានអោយគេ ទាំងមានព្រះបន្ទូលថា៖ "នេះជារូបកាយខ្ញុំ ដែលត្រូវបូជាសំរាប់អ្នករាល់គ្នា ចូរធ្វើដូច្នេះ ដើម្បីនឹករំឭកដល់ខ្ញុំ" » ។

(លូកា ២២:១៩)

កិច្ចការដែលត្រូវអនុវត្ត

- ចូលរួមធ្វើពិធីកាច់នំបុ័ងជាមួយក្រុមជំនុំរបស់អ្នកជានិច្ច ហើយរួមចិត្តគំនិតជាមួយព្រះគ្រីស្តជារៀងរាល់ថ្ងៃ ។
- និយាយប្រាប់ក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នក អំពីប្រស្នាស្តីអំពីដើមទំពាំងបាយជូរ ដោយប្រើរូបភាពបំភ្លឺ ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

© Project WorldReach © SEAN

យើងត្រូវរំលឹកឡើងវិញអំពីសេចក្តីបង្គាប់សំខាន់ៗទាំងប្រាំពីររបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត សំរាប់ពួកសិស្សរបស់ព្រះអង្គ :

១- ចូរនាំគ្នាកែប្រែចិត្តគំនិត ហើយជឿជំណឹងល្អចុះ ។ ចូរទទួលព្រះវិញ្ញាណ (ម៉ាកុស ១:១៥, យ៉ូហាន ២០:២២) ។

២- ទទួលពិធីជ្រមុជទឹក (ម៉ាថាយ ២៨:១៩) ។

៣- ត្រូវមានសេចក្តីស្រឡាញ់ (ម៉ាថាយ ២២:៣៧-៣៩) ។

៤- ចូលរួមធ្វើពិធីកាច់នំបុ័ង (លូកា ២២:១៩-២០) ។

៥- អធិស្ឋាន និងរិះគិតពិចារណាពីព្រះបន្ទូលព្រះជាម្ចាស់ (ម៉ាថាយ ៦:៩-១៣) ។

៦- ធ្វើអំណោយ (លូកា ៦:៣៨) ។

៧- បង្កើតសាវ័ក (ម៉ាថាយ ២៨:១៩) ។

តើសេចក្តីបង្គាប់ណាមួយដែលសំខាន់ជាងគេ ? _____

ព្រះយេស៊ូមានបន្ទូលថា÷ « *ប្រសិនបើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ អ្នករាល់គ្នាពិតជាកាន់តាមវិន័យរបស់ខ្ញុំ* » ។

(យ៉ូហាន ១៤:១៥)

បើអ្នករាល់គ្នាស្ថិតនៅជាប់នឹងខ្ញុំ ហើយបើពាក្យខ្ញុំស្ថិតនៅជាប់នឹងអ្នករាល់គ្នា ចូរទូលសុំអ្វីៗតាមតែអ្នករាល់គ្នាប្រាថ្នាចង់បានចុះ នោះអ្នករាល់គ្នាមុខតែបានទទួលជាមិនខាន ។ ព្រះបិតារបស់ខ្ញុំសំដែងសិរីរុងរឿង ដោយអ្នករាល់គ្នាបង្កើតផលផ្លែបានច្រើន និងដោយអ្នករាល់គ្នាជាសិស្សរបស់ខ្ញុំមែន » ។

(យ៉ូហាន ១៥:១-៨)

(សាវ័កប៉ូលមានប្រសាសន៍ថា) «*រីឯខ្ញុំ ខ្ញុំបានជំរាបបងប្អូនន្វសេចក្តីដែលខ្ញុំបានទទួលពីព្រះអម្ចាស់មកថា នៅយប់ដែលព្រះអម្ចាស់យេស៊ូត្រូវគេចាប់បញ្ជូនទៅឆ្កាង ព្រះអង្គយកនំបុ័ងមកកាន់ ទ្រង់អរព្រះគុណព្រះជាម្ចាស់ ហើយកាច់នំបុ័ងនោះ ទាំងមានព្រះបន្ទូលថា÷"នេះជារូបកាយខ្ញុំ ដែលត្រូវបូជាសំរាប់អ្នករាល់គ្នា ។ ចូរធ្វើដូច្នេះ ដើម្បីរំឭកដល់ខ្ញុំ" ។ លុះជប់លៀងរួចហើយ ព្រះអង្គធ្វើតាមបែបដដែល ទ្រង់យកពែងមកកាន់ទាំងមានព្រះបន្ទូលថា"នេះជាពែងនៃសម្ពន្ធមេត្រីថ្មី ចងឡើងដោយលោហិតរបស់ខ្ញុំ ។ គ្រប់ពេលដែលអ្នករាល់គ្នាពិសា ចូរធ្វើដូច្នេះដើម្បីរំឭកដល់ខ្ញុំ" ។ រៀងរាល់ពេលដែលបងប្អូនពិសានំបុ័ង និងពិសាពីពែងនេះ បងប្អូនប្រកាសអំពីព្រះអម្ចាស់សោយទិវង្គតរហូតដល់ព្រះអង្គយាងមកវិញ*»។

« ហេតុនេះ ប្រសិនបើអ្នកណាពិសានំបុ័ង និងពិសាពីពែងរបស់ព្រះអម្ចាស់ដោយមិនសមរម្យ អ្នកនោះនឹងមានកំហុស ដោយមិនបានគោរពព្រះកាយ និងព្រះលោហិតរបស់ព្រះអម្ចាស់ ។ ដូច្នេះ ម្នាក់ៗត្រូវពិនិត្យពិច័យមើលចិត្តគំនិតរបស់ខ្លួនឯងសិន សឹមពិសានំបុ័ង និងពិសាពីពែងរបស់ព្រះអម្ចាស់ ដ្បិតអ្នកណាពិសានំបុ័ង និងពិសាពីពែងនោះ ដោយមិនបានយល់ដល់ព្រះកាយរបស់ព្រះអម្ចាស់ទេ អ្នកនោះយកទោសមកដាក់លើខ្លួនឯងផ្ទាល់ » ។

(១ កូរិនថូស ១១:២៣-២៩)

តើនៅក្នុងពិធីកាច់នំបុ័ង នំបុ័ងតំណាងអ្វី ?

ឯពែងទឹកទំពាំងបាយជូរ តំណាងអ្វីដែរ ?

យោងទៅតាមអត្ថបទព្រះគម្ពីរដែលយើងបានអាន ដើម្បីចូលរួមធ្វើពិធីកាច់នំបុ័ងអោយបានត្រឹមត្រូវ តើយើងត្រូវធ្វើដូចម្តេច មុននឹងទទួលយកនំបុ័ង និងទឹកទំពាំងបាយជូរ ?

ពិធីកាច់នំបុ័ងតំណាងការរួមចិត្តគំនិតរបស់យើងជាមួយព្រះគ្រីស្ត ដោយសារព្រះគ្រីស្ត (១ កូរិនថូស ១០:១៦-១៧) ។ យើងនឹងធ្វើឱ្យការរួមចិត្តគំនិតគ្នានេះនៅស្ថិតស្ថេរ ដោយធ្វើតាមសេចក្តីបង្គាប់របស់ព្រះអង្គ ។

ព្រះគ្រីស្តមានបន្ទូលថា ព្រះអង្គជាដើមទំពាំងបាយជូរ ឯយើងជាមែក ។ យោងទៅតាមព្រះបន្ទូល តើយើងត្រូវធ្វើដូចម្តេច ដើម្បីបង្កើតផលផ្លែអោយបានច្រើន ?

បើសិនជាយើងមិននៅជាប់នឹងព្រះអង្គទេ តើនឹងមានការអ្វីកើតឡើង ?

ផលផ្លែដែលយើងបង្កើត ជាលទ្ធផលនៃការប្រតិបត្តិតាមព្រះ-ជាម្ចាស់ ដោយសេចក្តីស្រឡាញ់ ។